# ច្បាប់

# ស្តីអំពី

# ប្រព័ន្ធហិរញ្ញវត្ថុ

# ភាគមួយ
# បទបញ្ញត្តិទូទៅ

## ជំពូក ១
## អំពីច្បាប់ហិរញ្ញវត្ថុ

មាត្រា ១ .- ច្បាប់ហិរញ្ញវត្ថុគ្រោង និង អនុញ្ញាតសំរាប់ឆ្នាំនិមួយៗនូវសំណុំនៃធនធាន និងបន្ទុកទាំងអស់របស់រដ្ឋក្នុងក្របខ័ណ្ឌតំរង់ទិស និង គោលដៅរបស់ជាតិក្នុងវិស័យសេដ្ឋកិច្ច និង សង្គម ហើយនិងគិតគូរដល់ការថែរក្សាតុល្យភាពហិរញ្ញវត្ថុ និង រូបិយវត្ថុជាសារវន្ត ។

ច្បាប់ហិរញ្ញវត្ថុត្រូវបានអនុម័ត ដោយរដ្ឋសភា ។ ច្បាប់នេះត្រូវបានផ្សព្វផ្សាយ និង ប្រតិបត្តិទុកដូចជាមួយច្បាប់របស់ព្រះរាជាណាចក្រ ។

មាត្រា ២ .- លក្ខណៈច្បាប់ ហិរញ្ញវត្ថុ រួមមាន

១ - ច្បាប់ហិរញ្ញវត្ថុ ប្រចាំឆ្នាំ និង ច្បាប់កែសំរួលនានា

២ - ច្បាប់ទូទាត់ នៃថវិកា

មាត្រា ៣ .- គណនីថវិកា រួមមានថវិកាទូទៅរបស់រដ្ឋ និង គណនីពិសេសនៃរតនាគារ ។ គណនីថវិកាផ្សេងៗទៀត អាចបង្កើតបានក្នុងច្បាប់ហិរញ្ញវត្ថុ ។

មាត្រា ៤ .- ឆ្នាំថវិកាចាប់ផ្តើម នៅថ្ងៃទី ០១ ខែ មករា ហើយបញ្ចប់នៅថ្ងៃទី ៣១ ខែ ធ្នូ ។

មាត្រា ៥ .- បើសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុ មិនបានអនុម័តនៅមុនថ្ងៃទី ០១ ខែមករា នៃឆ្នាំ ថវិកាឆ្នាំមុនត្រូវបានបន្តដោយស្របច្បាប់ ក្នុងលក្ខខ័ណ្ឌខាងក្រោមនេះ :

១ - ការប្រមូលចំណូល សារពើពន្ធ ពន្ធគយ និងពន្ធគ្រប់ប្រភេទ ត្រូវបានបន្ត និងអនុញ្ញាតឱ្យប្រមូលក្នុងលក្ខខ័ណ្ឌ និង តាមបែបបទដែលបានកំណត់ដោយច្បាប់ហិរញ្ញវត្ថុដែលបានចែងពីមុន និងដោយនីតិកម្ម ព្រមទាំង បទបញ្ជាដែលមានជាធរមាន ។

២ - ចំណាយប្រក្រតីនៃថវិកា ក្រៅពីបន្ទុកបំណុលសាធារណៈ នៅតែបន្តប្រតិបត្តិតាមគំរោងនៃថវិកាឆ្នាំមុន ដោយគិតតាមវិធីមួយភាគដប់ពីរ ជាបណ្តោះអាសន្នក្នុងខែនិមួយៗ រហូតដល់មានអន្តរាគមន៍ពីថវិកាថ្មី ។

៣ - ចំណាយជាមូលធននៃថវិកា ក្រៅពីរំលស់នៃបំណុលសាធារណៈនៅតែបន្តប្រតិបត្តិតាមគំរោងនៃថវិកាឆ្នាំមុន ក្នុងក្របខ័ណ្ឌនៃឥណទានទូទាត់ដែលនៅទំនេរ ហើយអាចលើសពីនេះ បើសិនជាចាំបាច់ដោយមិនឱ្យការទូទាត់នោះលើសពីកំរិតឥណទានអនុញ្ញាតដែលបានអនុម័ត។

៤ - ចំណាយទាំងឡាយដែលទាក់ទងទៅនឹងសេវា និង ការរំលស់បំណុលសាធារណៈ ត្រូវបានរ៉ាប់រងជាបន្តបន្ទាប់មិនឱ្យដាច់តាមតារាងរំលស់ និងការប្រាក់ដែលបានព្រមព្រៀងត្រឹមត្រូវជាមួយគ្នា ។

## ជំពូក ២

## អំពីចរិកាទូទៅរបស់រដ្ឋ :
## ធនធាន និង បន្ទុក

### ផ្នែកទី ១ : ធនធានរបស់រដ្ឋ

មាត្រា ៦ ._ ធនធានអចិន្ត្រៃយ៍របស់រដ្ឋរួមមាន : ចំណូលប្រក្រតី និង ចំណូលជាមូលធន ដែលប្រមូលផ្ដុំ
ជា ៣ ប្រភេទ :

ប្រភេទមួយ : ពន្ធដារ និង ពន្ធអាករ

ប្រភេទពីរ : ចំណូលមិនមែនជាសារពើពន្ធ

ប្រភេទបី : ចំណូលជាមូលធន

ប្រភេទនិមួយៗ ត្រូវបានចែកជាជំពូក ជាប្រការ ជាកថាខ័ណ្ឌ និង ជាយថាហេតុ ជាវាក្យខ័ណ្ឌទៅតាមប្រភេទ ឬមុខសញ្ញានៃពន្ធ តាមផលទុន ឬផលិតផល ។ ចំណាត់ថ្នាក់នៃចំណូលនេះ ត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៧ ._ ពន្ធ និង អាករសំដៅលើ :

- ពន្ធលើផលទុន. លើប្រាក់ចំណេញ និង លើប្រាក់ចំណូលជាមូលធន
- ពន្ធលើរបតិកភ័ណ្ឌ
- ពន្ធផ្ទៃក្នុង លើទ្រព្យសម្បត្តិ និង សេវាកម្ម
- ពន្ធលើ ពាណិជ្ជកម្មក្រៅប្រទេស
- ចំណូលសារពើពន្ធផ្សេងទៀត

ចំណូលមិនមែនជាសារពើពន្ធ ទាក់ទងដល់

- ផលទុននៃទ្រព្យសម្បត្តិរដ្ឋ

ចំណូលមិនមែនជាសារពើពន្ធផ្សេងៗទៀត

ចំណូលជាមូលធនបានមកពី

- ចំណូលផ្ទៃក្នុង ជាមូលធន
- ជំនោយក្រៅប្រទេស
- ធនធានដែលខ្ចីពីគេ

មាត្រា ៨ ._ ពន្ធដារ និង ពន្ធអាករត្រូវបានកំណត់ ប្រមូល និង ត្រួតពិនិត្យ ។ អត្រានៃពន្ធ និង អាករ ។ អ្នកជាប់ពន្ធ ការលើកលែងពន្ធ ត្រូវបានកំណត់យ៉ាងច្បាស់លាស់ និងរឿងវិវាទដែលទាក់ទង ដល់បញ្ហាទាំងនេះ ត្រូវបានកំណត់ក្នុងលក្ខខ័ណ្ឌ និងតាមបែបបទ ដែលបានចែងដោយនីតិកម្ម និងការតាំងបទបញ្ជាដែលអាចអនុវត្តបានចំពោះប្រភេទនិមួយៗ នៃពន្ធអាករ ។

គ្មានបទបញ្ញត្តិណាមួយ ទោះជាប្រភេទណាក៏ដោយ គ្មានអនុសញ្ញាអន្តរជាតិណាមួយ ដែលអាចធ្វើឱ្យមានការប្រែប្រួល នាំមកនូវការបាត់ចំណូលនោះឡើយ ។ ករណីខាងលើ អាចប្រព្រឹត្តិទៅបាន លុះត្រាតែអនុវត្តតាមទំរង់ច្បាប់ និងបទបញ្ជាដូចខាងក្រោយពីមានយោបល់ ឯកភាពពីរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៩ ._ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវបានបំពេញយ៉ាងត្រឹមត្រូវទៅតាមបទបញ្ញត្តិនៃច្បាប់ និងនៃបទបញ្ជាជាធរមាន។

សមិទ្ធិកម្ម នៃទ្រព្យសង្ហារឹម និង អសង្ហារឹម ដែលជាចំណែកមួយនៃបេតិកភ័ណ្ឌជាតិ ត្រូវបានបញ្ចូលជាចាំបាច់នៅក្រោមអានុភាពនៃលក្ខខ័ណ្ឌ និង បែបបទដែលរៀបចំដោយនីតិកម្ម និង ការតាំងបទបញ្ជា ជាធរមាន ។

ក្រោមបទបញ្ញត្តិ នៃមាត្រា ១១ ខាងក្រោមនេះ ចំណូលទាំងអស់ដែលបានពីសមិទ្ធិកម្មខាងលើ ត្រូវបង់ចូលថវិកាទូទៅរបស់រដ្ឋ ដោយមិនអាចដកសោហ៊ុយដែលចេញពីកិច្ចប្រតិបត្តិការនោះឡើយ ។

ប្រតិបត្តិការជាលក្ខណៈពាណិជ្ជកម្ម ដែលទទួលធ្វើដោយអង្គភាពរបស់រដ្ឋដោយផ្ទាល់ ត្រូវបានដឹកនាំតាមទម្លាប់ប្រើប្រាស់ជាធរមានក្នុងវិស័យឧស្សាហកម្ម និង ពាណិជ្ជកម្ម ក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ១០ ._ សេវាដែលបង់ថ្លៃរបស់រដ្ឋឱ្យស្របទៅនឹងការផ្តល់សេវាទៅឱ្យឯកជន និងអង្គការគតិយុត្តដោយសេវាសាធារណៈរបស់រដ្ឋ ។ សេវាដែលបង់ថ្លៃ ត្រូវស្ថិតនៅក្រោមអនុភាពនៃតារាងតម្លៃដែលកំណត់ដោយរាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតាមយោបល់របស់ក្រសួង ដែលពាក់ព័ន្ធ ។

មាត្រា ១១ ._ ចំណូលត្រូវគត់ត្រាចូលទាំងស្រុង មិនត្រូវទូទាត់ជាមួយចំណាយឡើយ ។ ម្យ៉ាងទៀតហាមមិនឱ្យអាណាប័ក បង្កើនទឹកប្រាក់នៃឥណទានដែលបានអនុម័តក្នុងថវិកា ដោយសំអាងលើប្រាក់ចំណូលពិសេសណាមួយ ។

មាត្រា ១២ ._ចំណូលទាំងមូលត្រូវបានប្រើប្រាស់សំរាប់ទប់ទល់នឹងចំណាយទាំងអស់ ប៉ុន្តែចំណូលខ្លះអាចត្រូវបានចាត់ចែងសំរាប់ចំណាយខ្លះក្រោមរូបភាពនិងក្នុងលក្ខខ័ណ្ឌដែលត្រូវកំណត់ដោយច្បាប់។

# ផ្នែកពីរ : បន្ទុករបស់រដ្ឋ

មាត្រា ១៣ .- បន្ទុកអចិន្ត្រៃយ៍របស់រដ្ឋ រួមមានចំណាយប្រក្រតី និងចំណាយជាមូលធន ។ បន្ទុកនេះ ត្រូវចែកជាប្រាំប្រភេទថវិកា ។

មាត្រា ១៤ .-ចំណាយប្រក្រតីរបស់ថវិកា ត្រូវបានចាត់ថ្នាក់ទៅតាមលក្ខណៈរបស់វាជាបួនប្រភេទដូចតទៅៈ

ប្រភេទមួយ : មធ្យោបាយសេវាកម្ម

ប្រភេទពីរ : ការប្រាក់ដែលខ្ចីពីគេ

ប្រភេទបី : អន្តរាគមន៍ សាធារណៈ

ប្រភេទបួន : ចំណាយផ្សេងៗ និងពុំបានគ្រោងគិត

មាត្រា ១៥ .- ចំណាយជាមូលធននៃថវិកាគឺសំរាប់បំរើការប្រតិបត្តិកម្មវិធី ឬគំរោងការវិនិយោគ បំរើអន្តរាគមន៍ ជាមូលធនរបស់រដ្ឋទៅក្នុងវិស័យសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមរយៈសហគ្រាសរដ្ឋ ឬ បំរើមធ្យោបាយ នៃការចូលរួមប្រាស្រ័យ និងជាទីបំផុត បំរើការសងបំណុល ។

ចំណាយជាមូលធនថវិកា បង្កើតចេញប្រភេទទីប្រាំនៃថវិកា ។ ចំណាយទាំងនេះត្រូវបានចាត់ថ្នាក់ទៅតាមលក្ខណៈរបស់វា ចេញជាជំពូកថវិកា ដូចតទៅ :

- សាងសង់
- បរិក្ខារ
- កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ
- ការទូទាត់បំណុល

មាត្រា ១៦ .- ច្បាប់ហិរញ្ញវត្ថុបើកឥណទានទៅតាមក្រសួង ឬ អង្គការសាធារណៈប្រហាក់ប្រហែល និងទៅតាមប្រភេទសំរាប់ចំណាយ ។ ក្រសួង ឬអង្គការសាធារណៈប្រហាក់ប្រហែលទាំងនោះ ប្រមូលផ្តុំ ឥណទានទាំងអស់ សំរាប់បំរើការងាររបស់ខ្លួននៅទីក្រុងភ្នំពេញ និងនៅតាមគ្រប់ខេត្ត-ក្រុង ដែលជាខ្សែបណ្តាយរបស់ខ្លួន ។

មាត្រា ១៧ . ឥណទានទាំងអស់ដែលបានអនុញ្ញាតដោយច្បាប់ហិរញ្ញវត្ថុ ត្រូវបានរំលែកនៅក្នុងប្រភេទនិមួយៗទៅតាមលក្ខណៈ ឬ គោលដៅនៃឥណទានជាជំពូក ប្រការ កថាខណ្ឌ និង វាក្យខណ្ឌ ។ ចំណាត់ថ្នាក់នៃឥណទាននេះ ត្រូវបានបញ្ជាក់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ប្រភេទ ៤ នៃចំណាយប្រក្រតិ : ចំណាយផ្សេងៗ និងមិនបានគ្រោងគិត មិនត្រូវបានចាត់ចែងទៅឱ្យក្រសួង ឬ អង្គការសាធារណៈប្រហាក់ប្រហែលណាមួយទេ ។ ប្រភេទចំណាយនេះត្រូវបានទុកសំរាប់ចំណាយផ្សេងៗក្នុងការបេង ឬការបំពេញវិញដែលត្រូវគ្រប់គ្រងដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាឥណទានបង្ការទុក និងចំណាយពុំបានគ្រោងគិតដែរ ។

ឥណទានបង្ការទុកបណ្ដោះអាសន្ន ត្រូវបានបើកសំរាប់ចំណាយទាំងឡាយណា ដែលការបែងចែក មិនអាចត្រូវបានកំណត់ជាក់លាក់នៅពេលឥណទានត្រូវបានអនុម័ត ។ ការចាត់ចែងឥណទានបង្ការទុកទាំងនេះត្រូវបានសំរេចដោយក្រឹត្យរបស់រាជរដ្ឋាភិបាលលើសំណើរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ១៨ .- ឥណទានថវិកា មានលក្ខណៈកំហិត ឬ អាចវាយតម្លៃបាន ។

ឥណទានកំហិតកំណត់កំរិតខ្ពស់ ដែលនាំក្នុងនោះត្រូវតែមានការភ្ជាប់សន្យា និង ការចេញបញ្ជានៃចំណាយប្រភេទនេះ ។ ចំណាយរបៀបនេះ អាចបង្កើនបានដោយច្បាប់ហិរញ្ញវត្ថុ កែតម្រូវតែមួយគត់ក្នុងលក្ខខ័ណ្ឌនៃបទបញ្ញត្តិ មាននៅភាគទីបីក្រោយនេះ ។

ឥណទានដែលវាយតម្លៃបាន ទាក់ទិនតែចំណាយមានលក្ខណៈចាំបាច់ដែលក្នុងពេលបង្កើតថវិកា ធ្វើជាកម្មវត្ថុសំរាប់ការគ្រោងមួយដែលក្រោយនេះមិនបានគ្រប់គ្រាន់ ។ ចំណាយនៃឥណទានប្រភេទនេះអាចនឹងត្រូវបានប្រតិបត្តិហួសពីទាយជ្ជទានបានគ្រោង ដោយជំពូកថវិកាពាក់ព័ន្ធ ។ ឥណទានប្រភេទនេះកើតមានលើបំណុលសាធារណៈ បៀវត្សប្រាក់បំណាច់របស់បុគ្គលិក និង ជាទូទៅចំណាយដូចបានបរិយាយដោយច្បាប់ហិរញ្ញវត្ថុ ។

មាត្រា ១៩ .- ឥណទានទាក់ទិនដល់ចំណាយប្រក្រតី ត្រូវបានបែងចែកតាមសេវាដែលបានអនុម័ត និង តាមការរៀបចំថ្មីៗ ។

សេវាដែលបានអនុម័ត តំណាងដោយឥណទានបានចុះក្នុងថវិកាចំណាយជាប្រចាំ នៃឆ្នាំមុន និងបានកាត់បន្ថយទាយជ្ជទានមិនអាចកែប្រែថ្មី និង ឬកបន្ថែមឥណទានសំរាប់ការកែតម្រូវតាមសេចក្ដីត្រូវការ ។ សេវាដែលបានអនុម័តត្រូវស្របទៅនឹងអប្បបរិមា នៃឥណទានចាំបាច់ សំរាប់បំរើសេវាសាធារណៈ ក្នុងលក្ខខ័ណ្ឌនៃឆ្នាំមុន ។

ការកែតម្រូវទៅតាមសេចក្ដីត្រូវការ ត្រូវគិតវាំពីផលប៉ះពាល់ក្នុងឆ្នាំដែលរាល់វិធានការជ្រើសរើសទាំងអស់បានធ្វើឆ្ពោះទៅរកការគ្រប់គ្រងមុនៗ និងទៅរកការវិវត្តន៍មិនអាចជៀសបាន នៃបន្ទុកសាធារណៈខ្លះៗ ។

វិធានការថ្មីៗ មានចរិតជាការសំរេច ដែលនាំមកនូវផលប៉ះពាល់ហិរញ្ញវត្ថុបន្ថែមលើថវិកា ។

មាត្រា ២០ .- ឥណទានសំរាប់ចំណាយជាមូលធន ត្រូវបានបែងចែកជាឥណទានសំរាប់កម្មវិធី ឥណទានសំរាប់ភ្ជាប់សន្យា និងជាឥណទានសំរាប់ទូទាត់ ។

ឥណទានសំរាប់កម្មវិធី កំណត់កម្មវិធី ឬគម្រោងការទាំងឡាយដែលរដ្ឋអាចដាក់ចេញក្នុងឆ្នាំថវិកា និងកម្រិតបរិយាទានសរុបសំរាប់កិច្ចការទាំងនោះ។ ឥណទានសំរាប់កម្មវិធីត្រូវបំផុសឱ្យឃើញពីចំណាយទាក់ទិនទៅនឹងការប្រតិបត្តិទាំងស្រុងនៃគម្រោងការ ឬក៏ការប្រតិបត្តិមួយចំណែកណានោះ ដោយគ្មានការបូកបន្ថែមផ្សេងៗ រហូតដល់ពេលដាក់ឱ្យប្រើ ។

ទោះជាយ៉ាងនោះក្តី ក៏ឥណទានសំរាប់កម្មវិធី អាចអូសទាញរហូតមកត្រឹមតែរង្វង់នៃឥណទានសំរាប់ភ្ជាប់សន្យា ដែលបានអនុម័តដោយច្បាប់ហិរញ្ញវត្ថុតែប៉ុណ្ណោះ ។

ឥណទានសំរាប់ភ្ជាប់សន្យា ត្រូវបានដាក់ក្រោមអាណាប័ក សំរាប់ឱ្យគេអាចធ្វើចំណាយបាំបាច់ទាំងឡាយដល់ការប្រតិបត្តិអំពីវិនិយោគបានគ្រោងដោយច្បាប់ហិរញ្ញវត្ថុ ។

ឥណទានសំរាប់ទូទាត់ ត្រូវបានទុកឱ្យការចេញបញ្ជាចំណាយ អំពីប្រាក់បានដាក់ជាបន្ទុកដល់រដ្ឋ ក្នុងក្របខ័ណ្ឌនៃឥណទានភ្ជាប់សន្យាស្របគ្នា ។

មាត្រា ២១ ._ ឥណទានភ្ជាប់សន្យា អាចមានតម្លៃគ្មានកំណត់ពេល ។ ឥណទាននេះត្រូវបានយោងពីមួយឆ្នាំទៅមួយឆ្នាំ រហូតដល់ការលុបបំបាត់ជាយថាហេតុ ។ ឥណទានសំរាប់ទូទាត់ដែលមិនបានប្រើនៅពេលបិទការគ្រប់គ្រង "បញ្ចប់ឆ្នាំ" ត្រូវបានលុបចោល និងអាចអនុញ្ញាត ឥណទានថ្មីសំរាប់ឆ្នាំបន្ទាប់ ។

មាត្រា ២២ ._ គ្មានវិធានការណ៍ជានីតិបញ្ញត្តិ បទបញ្ជា ឬរដ្ឋបាលណាមួយអាចត្រូវបានអនុម័ត. ទទួល ស្គាល់ ឬសំរេច បើវិធានការណ៍នោះបង្កឱ្យមានបន្ទុកថ្មីដែលបានគ្រោងទុកជាមុនក្នុងថវិកា ។ នៅក្នុងផែនការថវិកាការប្រែប្រួល របស់អង្គភាពស្រង់គិតដល់ ការសន្សំសំចៃដែលអាចមានអនុភាពដោយបន្ទុកសាធារណៈ ។

ការបង្កើត និង ការប្តូរមុខរបរ ក៏ដូចជាការប្រឡងជ្រើសរើសអាចកើតមានតែពិតារាងមុខរបរដែលបានកំណត់ដោយរដ្ឋបាល ឬអង្គភាព និងបានគ្រោងដោយថវិកា ។ គ្មានវិធានការណ៍តម្លើងឋានៈ ឬបង្កើតជំនាន់មន្ត្រីរាជការ ផ្តល់បុព្វលាភថ្មី ឬបង្កើនលាភការមិនអាចសំរេចបានទេ បើប្រសិនណាវិធានការណ៍ទាំងនេះមិនបានបំពេញដោយឥណទានគ្រប់គ្រាន់បើកផ្តល់ជាមុនដោយថវិការដ្ឋ ។

តែបទបញ្ញត្តិទាំងអស់របស់មាត្រានេះ មិនស្រូវបានអនុវត្តដោយអនុសញ្ញាហិរញ្ញវត្ថុដោយការធានាយល់ព្រមពីរដ្ឋ និង ដោយបំណុលសាធារណៈ ។

## ជំពូក ៣
## គណនីពិសេសរបស់រតនាគារ

មាត្រា ២៣ ._ គណនីពិសេសរបស់រតនាគារ បង្កើតបានជាគណនីបំពេញបន្ថែមរបស់រតនាគារ និងទុកសំរាប់ៈ

១ _ ចុះកិច្ចការចំណូលដោយឡែក ជាហិរញ្ញប្បទានជាក់លាក់លើសកម្មភាពណ៍នានាទាំងឡាយ : គឺជាគណនីជាក់ស្តែងពិសេស ;

២ _ បង្ហាញចំណាយរបស់រដ្ឋមានលក្ខណៈមិនទៀងទាត់ : គឺជាគណនីបុរេប្រទាន

៣ _ កត់ត្រាប្រតិបត្តិការទាំងអស់ មានលក្ខណៈឧស្សាហកម្ម ឬពាណិជ្ជកម្មដែលបាន ធ្វើដោយរដ្ឋជាលក្ខណៈបន្ទាប់បន្សំ : គឺជាគណនីពាណិជ្ជកម្ម ។

គណនីពិសេសទាំងអស់របស់រតនាគារ ត្រូវបានបង្កើត ឬ លុបចោលដោយច្បាប់ហិរញ្ញវត្ថុ ក្រោមលក្ខខ័ណ្ឌនៃបទបញ្ញត្តិនៃច្បាប់ "ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ" នេះ ចំណាត់ការនៃគណនីពិសេសទាំងអស់របស់រតនាគារ ត្រូវបានកំណត់ដោយផ្លូវច្បាប់ ។

មាត្រា ២៤ ._ ចំណូល និង ចំណាយទាំងអស់នៃគណនីពិសេសរបស់រតនាគារត្រូវបានគ្រោង និងអនុញ្ញាត ក្នុងលក្ខខ័ណ្ឌដូចគ្នាទៅនឹងប្រតិបត្តិការថវិកាទូទៅដែរ ។

មាត្រា ២៥ ._ ប្រតិបត្តិការចំណាយ ដែលអាចផ្ទុកលើគណនីពិសេសរបស់រតនាគារ ត្រូវបានប្រព្រឹត្តទៅដូចជាមុខការថវិកាដែរ ក្រោមលក្ខខ័ណ្ឌនៃចំណុចដោយឡែកដូចតទៅ :

១ _ សរុបចំណាយគិតគូររួចហើយ ឬ បានចេញអាណត្តិទៅឱ្យគណនីពិសេសនៃរតនាគារ មិនអាចលើសពីសរុបធនធានរបស់គណនីដូចគ្នា.

២ _ ក្នុងរយៈពេលគ្រប់គ្រង បើប្រសិនណាជា ចំណូលរបស់គណនីពិសេសនៃរតនាគារ ដែលចំណាយទាំងអស់ មានលក្ខណៈជាន់ប្រមាណបានស្តែងឡើងខ្ពស់ពីការវាយតម្លៃនោះ ឥណទាននៃគណនីនេះ អាចត្រូវបានតម្លើងដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងកំរិតនៃចំនួនលើសរបស់ចំណូលដែលបានកត់ត្រា.

៣ _ សមតុល្យឥណទាយី នៃគណនីពិសេសទាំងនេះរបស់រតនាគារ អាចយោងពីមួយឆ្នាំទៅមួយឆ្នាំ លើកលែងតែមានបទបញ្ញត្តិផ្ទុយ ដែលបានគ្រោងដោយច្បាប់ហិរញ្ញវត្ថុ

៤ _ ហាមឃាត់មិនឱ្យចុះលើគណនីពិសេសនៃរតនាគារ នូវរាល់ចំណាយណាដែលមិនចូលក្នុងក្របខ័ណ្ឌនៃកម្មវត្ថុរបស់គណនីនេះ ជាអាទិ៍បៀវត្ស ឬប្រាក់បំណាច់ ។

# ភាគពីរ
# ការរៀបចំ និង ការអនុម័តថវិកា

## ជំពូក ៤
## អំពីការរៀបចំថវិកា

### ផ្នែកទី ១ អំពីបរិបទ និង ប្រតិទិនថវិកា

មាត្រា ២៦ ._ ស្ថិតក្រោមអំណាចនៃនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំគម្រោងថវិកាដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ ក្នុងលក្ខខ័ណ្ឌជាក់លាក់ដូចតទៅ

រៀងរាល់ឆ្នាំ នៅខែមិនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំទស្សនវិស័យនៃថវិកាឆ្នាំបន្ទាប់ ដោយឆ្លងកាត់តាមការវិភាគនៃស្ថានការណ៍សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្ពត្តិកម្មទាំងឡាយនៃការវិវត្តន៍ នៃស្ថានភាពក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម និងការតៀបសង្កត់នៃម៉ាក្រូសេដ្ឋកិច្ច ដែលអាចកើតមាន ។

នៅក្នុងក្របខ័ណ្ឌនេះ រដ្ឋាភិបាលកំណត់នូវអាទិភាពជាតិ និងការជ្រើសរើសដោយសមស្រប ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បង្កើតឃើញឈ្មោះទាំងនេះ នូវចំនួនសរុបនៃគំរោងថវិកា ចែកចេញជាចំណូលនិងជាចំណាយ និងរៀបចំសេចក្តីព្រាងដំបូងនៃថវិកាដែលមានលក្ខណៈជារួមដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រី ។

សេចក្តីព្រាងដំបូងនៃថវិកា បានអនុម័តពីរាជរដ្ឋាភិបាលក្រោមរូបភាពជាទិសដៅដែលកំណត់នូវលក្ខខ័ណ្ឌទាំងឡាយជាកំណត់ ក្នុងនោះត្រូវរៀបចំសំណើថវិកាសំរាប់ឆ្នាំបន្ទាប់ វិភាគ ទិន្នន័យសំខាន់ៗ នៃស្ថានការណ៍សេដ្ឋកិច្ចជាទូទៅ និងផលវិបាកដែលអាចកើតមាន ដើម្បីធានាតុល្យភាពជាគោលសំខាន់ និង កំណត់ចំនួនថវិកាសរុបតាមក្រសួង ឬ អង្គការប្រហាក់ប្រហែល និងតាមប្រភេទចំណាយទាំងឡាយ ។

ព្រមជាមួយគ្នា រដ្ឋមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរៀបចំ និងផ្ញើជូនរដ្ឋអំណាចទាំងឡាយនូវសារាចរថវិកា មានលក្ខណៈជាបច្ចេកទេសបញ្ជាក់ពីបែបបទនៃការបង្កើតគំរោង ពីវិធីវាយតម្លៃ ដែលត្រូវអនុវត្តពីការបង្ហាញជូនសំរាប់អនុម័តនិងឯកសារយុត្តិការដែលត្រូវផ្តល់ជូន។

រដ្ឋមន្ត្រីគ្រប់ក្រសួង នាយកគ្រប់ស្ថាប័នរដ្ឋបាលបង្កើតគំរោងចំណាយ ចំណូលជាកំណត់របស់ខ្លួនសំរាប់រដ្ឋអំណាចកណ្តាល សំរាប់អង្គភាពខាងក្រៅទាំងឡាយរបស់ខ្លួននៅតាមខេត្តនានា និងអង្គភាពក្រោមឱវាទ ។ គំរោងទាំងនេះត្រូវផ្ញើមករដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅខែ កញ្ញា ។

នៅខែកញ្ញា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រមូលផ្តុំគ្រប់សំណើចំណាយ ពិនិត្យ និងពិភាក្សាជាមួយរដ្ឋមន្ត្រីពាក់ព័ន្ធ ធ្វើការកែតម្រូវនូវអ្វីចាំបាច់ស្របតាមបញ្ញត្តិ នៃការណែនាំថវិកា និងបន្ថែមលើគំរោងចំណូល នូវអ្វីចាំបាច់ទាំងនោះ ។

នៅខែវិច្ឆិកា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កសាងនូវគំរោងច្បាប់ហិរញ្ញវត្ថុដែលពិនិត្យ និងឯកភាពពីរាជរដ្ឋាភិបាល ហើយដាក់ជូនរដ្ឋសភាជាតិនៅអាទិត្យទីខែធ្នូ ដើម្បីពិភាក្សា និងអនុម័ត មុនថ្ងៃទី២៥ ខែធ្នូ ។

## ផ្នែកទី ២ _ អំពីការប៉ាន់ស្មានចំណូល

មាត្រា ២៧ ._ ការប៉ាន់ស្មានចំណូល គឺអាស្រ័យទៅលើប្រភពនៃផលិតផល ឬ ផលទុន ។

១ _ ចំណូលថវិកាបានមកពីសារពើពន្ធ ពន្ធគយ អាករផ្សេងៗទៀត និង ពីផលនៃទ្រព្យសម្បត្តិរដ្ឋ ទាំងនោះគឺជាកម្មវត្ថុប៉ាន់ស្មានដោយផ្ទាល់ពីសំណាក់ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះគ្រប់ផលដែលត្រូវប្រមូល ។ ការប៉ាន់ស្មានលើចំណូលពីសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធ បានមកពីសហគ្រាសសាធារណៈនៅថ្នាក់កណ្តាល និង នៅថ្នាក់ខេត្ត ក៏ត្រូវបានប្រមូលផ្តុំគិតគូរដែរ ដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

២ _ ក្រសួងទាំងឡាយ និង អង្គការសាធារណៈប្រហាក់ប្រហែលក្រោមឱវាទដែលមានផ្នែកគ្រប់គ្រងចំណូល ត្រូវផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវបញ្ជីរាយមុខចំណូលនិងបញ្ជីប៉ាន់ស្មានដែលទាក់ទង ដើម្បីចុះក្នុងសារបែបចំណូលថវិកាឱ្យបានត្រឹមត្រូវ ។ ចំណូលទាំងនេះជាចំណែកមួយក្នុងចំណូលសរុបនៃថវិកាទូទៅរបស់រដ្ឋ ។

មាត្រា ២៨ ._ ការវាយតម្លៃនៃចំណូលសារពើពន្ធនិងពន្ធគយ ត្រូវបានប្រតិបត្តិការ អំពី :

- ប្រាក់ចំណូលដែលយើងទទួលបាន នៃឆ្នាំ
- គិតគូរយល់ឥទ្ធិពលដែលជះមកពីអតិផរណា ទៅលើមូលដ្ឋានគិតពន្ធ
- ប៉ាន់ស្មានលើការវិវត្តន៍សេដ្ឋកិច្ចពេលខាងមុខ
- ការប្រែប្រួលដែលកើតមានហើយ ឬត្រូវពិចារណាលើអត្រា និងលើមូលដ្ឋានប្រមូលពន្ធ
- ផលចំណូល បានមកពីការបង្កើតអាករថ្មី ។

មាត្រា ២៩ ._ ការប៉ាន់ស្មានចំណូលជាមូលធន ត្រូវបង្កើតឡើងអាស្រ័យដោយ ធនធានបានមកពី :

១ _ ផលបានមកពីសមិទ្ធផលនៃបេតិកភ័ណ្ឌចលនៈកម្ម ឬ អចលនៈកម្មរបស់រដ្ឋ គឺជាកម្មវត្ថុនៃការប៉ាន់ស្មានពីសំណាក់គ្រប់ក្រសួង និងអង្គការសាធារណៈប្រហាក់ប្រហែល ដែលជាអ្នកអនុវត្តកិច្ចប្រតិបត្តិការនោះ ។ ចំនួនផលទាំងនេះត្រូវចុះក្នុងចំណូលពីមូលធន ក្នុងថវិកាទូទៅ។

២ _ ការសងបំណុល និង សងបុរេប្រទានជាយថាហេតុអនុញ្ញាតិដោយថវិកាដល់សហគ្រាសសាធារណៈ នោះត្រូវចុះឱ្យបានត្រឹមត្រូវក្នុងតារាងវិលស់ ។

៣ _ ប្រភពចំណូលផ្សេងៗពីការខ្ចីបុលក្នុងប្រទេស ក្នុងពេលប្រភពចំណូលនេះសំរេចយល់ព្រមពី រាជរដ្ឋាភិបាល ត្រូវវាយតម្លៃផ្ទាល់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយទំនាក់ទំនងជាមួយធនាគារជាតិកម្ពុជា ដោយវិភាគបរាងច្បាស់លើស្ថានការណ៍សេដ្ឋកិច្ច និង លក្ខណៈចរិតនៃការខ្ចីជាយថាហេតុទាំងនោះ។

៤ _ ជំនួយក្រៅប្រទេសក្រោមរូបភាពជាអំណោយ ឬ ការខ្ចីបុល ត្រូវចុះក្នុងថវិកាទូទៅ ចាត់ទុកជាបន្ទុក ឬ ចាត់ទុកជាការហោរអាស្រ័យដោយលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចព្រមព្រៀង ។ ប្រភពបានមកពីគំរោងជំនួយ ត្រូវវាយតម្លៃតាមការប្រើប្រាស់វិញនូវមូលនិធិដែលគ្រោងទុកជាមុន ដោយទំនាក់ទំនងទៅនឹងបុរេប្រទាននៃគំរោង ។ មូលនិធិបដិភាគដែលមាន នៅក្នុងថវិកាទូទៅ ស្មើនឹងសរុបទឹកប្រាក់ចំណាយខាងមុខ ក្នុងនោះរួមមានទាំងសមិទ្ធិផលអាចប្រមាណបាន លើការនាំចូលតាមផែនការ ។

# ផ្នែកទីបី : អំពីគំរោងចំណាយ

មាត្រា ៣០._ គំរោងចំណាយជាប្រក្រតី និង គំរោងចំណាយជាមូលធន ត្រូវរៀបចំឡើងដោយក្រសួងទាំងឡាយ និងអង្គការប្រហាក់ប្រហែលដោយគិតបញ្ចូលទាំងអង្គភាពរបស់ខ្លួនរដ្ឋបាលកណ្តាល អង្គភាពខាងក្រៅ និង គ្រប់សកម្មភាពរបស់ខ្លួន ។

មាត្រា ៣១._ ការវាយតម្លៃទៅលើសេចក្តីត្រូវការទាំងឡាយ បានបង្កើតឡើងដោយផ្អែកទៅលើកម្មវិធីសកម្មភាព និងទៅលើទិសដៅនៃលទ្ធផលទទួលបានដោយកំណត់យ៉ាងច្បាស់លាស់ និងរក្សាទុករាល់ខ្ទង់ចំណាយដែលមាននៅក្នុងកម្មវិធី ។ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បង្កើតឡើងដោយទំនាក់ទំនងទៅនឹងក្រសួងពាក់ព័ន្ធ នូវនិយាម ឬ ឯកត្តារង្វាស់រង្វាល់ សំរាប់សកម្មភាព ដ៏សំខាន់ៗ ក៏ដូចគ្នាដែរចំពោះសេវា និងផលប្រើប្រាស់ជាប្រចាំ ។

មាត្រា ៣២._ ការចំណាយជាមូលធនទាំងឡាយ ដែលទាក់ទងទៅនឹងកម្មវិធី ឬ ទាក់ទងដល់គំរោងដោយឡែក ដែលមានការយល់ព្រមពីមុនមក គឺសំដៅទៅលើគោលដៅ ដែលអាចទទួលបានយ៉ាងជាក់ស្តែងរាល់កម្មវិធី ឬគំរោង គឺជាមុខសញ្ញានៃការវាយតម្លៃ សំរាប់ចំណាយសរុបរបស់កម្មវិធី និងគំរោងនោះ និងជាមុខសញ្ញាសំរាប់វាយតម្លៃរយៈពេលកំណត់ នឹងចង្វាក់នៃការទូទាត់សំរាប់ដំណាក់កាលនិមួយៗក្នុងឆ្នាំ ។

# ផ្នែកទីបួន : បទបញ្ញត្តិផ្សេងៗ

មាត្រា ៣៣._ ក្នុងគោលបំណងគោរពពេលវេលាជាចាំបាច់ ក្នុងការបង្កើតគំរោងនៃច្បាប់ហិរញ្ញវត្ថុ និងក្នុងការពិនិត្យ និងយល់ព្រមដោយរាជរដ្ឋាភិបាល និងសភាជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បង្កើតដោយពេញសិទ្ធនូវសមិទ្ធិផលទាំងឡាយដែលទទួលបាននៃឆ្នាំ នូវគំរោងចំណាយដែលក្រសួងទាំងឡាយ និងអង្គការសាធារណៈប្រហាក់ប្រហែល មិនបានលើកគំរោងរបស់ខ្លួនក្នុងពេលវេលាដែលបានកំណត់ ។

## ជំពូក ៥
## អំពីកំណត់បង្ហាញ និងការអនុម័តថវិកា

មាត្រា ៣៤._ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុដាក់បង្ហាញជូនសភាជាតិ ត្រូវភ្ជាប់ជាមួយនូវ :

១ _ របាយការណ៍សរុបមួយ វិភាគពីចរិតលក្ខណៈថវិកាថ្មី និង ឱ្យអត្ថន័យច្បាស់លាស់ពីតុល្យភាព សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

២ _ កំណត់ពន្យល់រាយតាមជំពូកនិមួយៗ សំរាប់ការចំណាយប្រក្រតី ដោយវិភាគលើសរុបឥណទានធ្វើឱ្យឃើញចេញនូវការកើនឡើងនៃតម្រូវការ និង បង្ហាញភស្តុតាងនូវការកត់ត្រាឥណទាន ពាក់ព័ន្ធ យ៉ាងណាទៅនឹងសេវា ដែលបានអនុមតិឆ្នាំមុនក៏ដូចតម្រឹមទៅនឹងតម្រូវការ និង វិធានការថ្មីដែលមានសារសំខាន់ចាំបាច់សំរាប់ការគ្រប់គ្រងថ្មី ។

៣ _ ឧបសម្ព័ន្ធចងក្រងជាជំពូក និង តាមគំរោងដើម្បីការចំណាយទាំងឡាយជាមូលធន រំលឹកឥណទានភ្ជាប់សន្យា និង ទូទាត់ការបើកផ្តល់សំរាប់គំរោងក្នុងឆ្នាំគ្រោងបំរុងឥណទាន ដែលមានប្រភេទចាំបាច់ដូចគ្នាទៅនឹងការបន្តគំរោងទាំងនេះ និងវិភាគគំរោងថ្មី និង តម្រូវការ ឥណទានរបស់វាដោយកំណត់តាមប្រតិទិនប្រើប្រាស់ដែលបានគ្រោងទុក ។

៤ _ ឯកសារចាំបាច់ផ្សេងទៀត ចាំបាច់សំរាប់ពត៌មាន និងសំរាប់ការត្រួតពិនិត្យរបស់សភាជាតិ ។

មាត្រា ៣៥._ គំរោងច្បាប់ហិរញ្ញវត្ថុចែកចេញជាពីរផ្នែក ។ ផ្នែកទី១ ច្បាប់អនុញ្ញាតិឱ្យប្រមូលគ្រប់ធនធានសាធារណៈ និងកំណត់ធនធានទាំងនោះជាទឹកប្រាក់សរុប ។ ច្បាប់បានកំណត់នូវផ្លូវ និងមធ្យោបាយអនុវត្តចំពោះការចំណាយជាមូលធន ។ ច្បាប់បានកំណត់នូវឥណទានចំហរខ្ពស់បំផុតដែលជាគុណប្រយោជន៍ដល់ថវិកាទូទៅ និងគណនីពិសេសរបស់រតនាគារ. ច្បាប់រួមមានបទបញ្ញត្តិទាំងឡាយដែលទាក់ទងដល់ចំណូលសារពើពន្ធ និង ទាក់ទងដល់គ្រប់បទបញ្ញត្តិហិរញ្ញវត្ថុផ្សេងទៀត ។ ផ្នែកទី២ រួមមានតារាងកំណត់ចេញជាជំពូក ប្រការ កថាខណ្ឌ និង វាក្យខណ្ឌ ដែលទាក់ទងដល់ចំណូលប្រក្រតីរបស់ថវិកាទូទៅ ។ ច្បាប់មានគំរោងចំណាយប្រក្រតីរបស់ថវិកាទូទៅបែងចែកតាមក្រសួង និងអង្គការសាធារណៈប្រហាក់ប្រហែល និងបែងចែកតាមប្រភេទ

ចំណាយ និងចែកចេញជាសេវាដែលបានអនុម័ត និងវិធានការថ្មីៗទៀត ។ ច្បាប់ញែកផ្លូវ និងមធ្យោបាយអនុវត្ត សំរាប់ចំណាយជាមូលធននៃថវិកា និងកម្មវិធីឥណទាន និងបែងចែកចំណាយជាមូលធន តាមក្រសួង និងអង្គការសាធារណៈប្រហាក់ប្រហែលជាជំពូក ដោយធ្វើឱ្យចេញជា ឥណទានភ្ជាប់សន្យា និងឥណទានទូទាត់ ។ ច្បាប់បញ្ឈប់បញ្ជីរបស់គណនីពិសេសរបស់រតនាគារ ដែលមានលក្ខណៈរដ្ឋបាល និង កំណត់សំរាប់គណនីពិសេសនិមួយ ៗ នូវចំនួនទឹកប្រាក់ចំណូល និងចំនួនទឹកប្រាក់ចំណាយ ។

មាត្រា ៣៦._ច្បាប់ហិរញ្ញវត្ថុ ត្រូវបានអនុម័តក្នុងលក្ខខ័ណ្ឌដូចគ្នានឹងច្បាប់ធម្មតាទាំងឡាយ ក្នុងបទបញ្ញត្តិដោយឡែកដូចខាងក្រោមនេះ :

១ _ គំរោងចំណូលគឺជាកម្មវត្ថុ នៃ :
- ការអនុម័តសរុប សំរាប់ចំណូលប្រក្រតី
- ការអនុម័តសរុប សំរាប់ចំណូលជាមូលធន
- ការអនុម័ត តាមគណនេយ្យពិសេស នៃរតនាគារ

២ _ គំរោងចំណាយគឺជាកម្មវត្ថុ នៃ :
- ការអនុម័តតាមក្រសួង ឬ អង្គការសាធារណៈប្រហាក់ប្រហែល និង តាមប្រភេទសំរាប់ចំណាយប្រក្រតី
- ការអនុម័តតាមក្រសួង ឬ អង្គការសាធារណៈប្រហាក់ប្រហែល និង តាមប្រភេទសំរាប់ចំណាយជាមូលធន និង អនុម័តតាមគណនេយ្យពិសេសនៃរតនាគារ ។

៣ _ បទបញ្ញត្តិទាំងអស់នៃច្បាប់ហិរញ្ញវត្ថុ គឺជាកម្មវត្ថុនៃការអនុម័តចុងក្រោយបង្អស់ ។

មាត្រា ៣៧._ គ្មានមាត្រាបន្ថែមណាមួយ និងគ្មានវិសោធនកម្មទៅលើគំរោងច្បាប់ហិរញ្ញវត្ថុណាមួយប្រព្រឹត្តទៅបានទេ បើមិនសំដៅទៅលើការលុបចេញ ឬបន្ថយចំណាយ បង្កើត ឬបន្ថែមអត្ថចំណូលណាមួយនោះ ។

គ្រប់សំណើចំណាយថ្មីៗទាំងអស់ ត្រូវផ្តើមចេញពីសំណើយន្តកិច្ចស្មើនឹងចំនួន ទឹកប្រាក់លើសរុបចំណាយទាំងអស់ ។

មាត្រាបន្ថែម ឬវិសោធនកម្ម ដែលប្រព្រឹត្តទៅល្មើស និងបទបញ្ញត្តិទាំងនេះត្រូវកាត់ចេញដោយពេញសិទ្ធ ។

មាត្រា ៣៨.- ការបែងចែកឥណទានចំហរជាជំពូកដោយច្បាប់ហិរញ្ញវត្ថុ ជាគុណប្រយោជន៍ដល់ថវិកាទូទៅនោះ ត្រូវប្រព្រឹត្តទៅដោយក្រឹត្យ របស់រាជរដ្ឋាភិបាល ។

ក្រឹត្យបែងចែកនេះ មិនអាចនាំមកនូវការប្រែប្រួលឥណទានអនុម័តដោយសភាជាតិលើមូលដ្ឋាន នៃសំណើទាំងឡាយដែលមាននៅក្នុងអត្ថបទពន្យល់ជាឧបសម្ព័ន្ធនោះទេ ។

មាត្រា ៣៩.- ការបែងចែកលំអិតនៅក្នុងជំពូក ប្រការ កថាខ័ណ្ឌ វាក្យខ័ណ្ឌ នៃឥណទានទាំងឡាយអនុវត្តទៅលើមាត្រាមុន ត្រូវប្រព្រឹត្តទៅដោយប្រកាសរបស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ភាគបី
## អំពីការអនុវត្តន៍ ថវិកា

### ជំពូក ៦
### ចលនាឥណទានថវិកា

មាត្រា ៤០.- ការផ្ទេរឥណទាន ពីក្រសួងមួយ ឬ អង្គការសាធារណៈថ្នាក់ប្រហាក់ប្រហែលណាមួយ ទៅក្រសួង ឬអង្គការសាធារណៈមួយផ្សេងទៀត ដោយភាពចាំបាច់នៃការងារពង្រឹងរចនាសម្ព័ន្ធរបស់រដ្ឋាភិបាល ឬ រដ្ឋបាលអាចប្រព្រឹត្តទៅដោយក្រឹត្យរបស់រាជរដ្ឋាភិបាល លុះត្រាតែការផ្ទេរឥណទានទាំងនេះ មិនកែប្រែប្រភេទចំណាយ និងការបែងចែកឥណទាន តាមជំពូកនានា ។

មាត្រា ៤១.- ការបង្វែរឥណទានពីជំពូកមួយ ទៅជំពូកមួយ អាចប្រព្រឹត្តទៅបានដោយក្រឹត្យ ក្នុងក្របខ័ណ្ឌអន្តរាគមន៍ផ្ទៃក្នុងនៃប្រភេទតែមួយដូចគ្នា របស់ក្រសួង ឬ អង្គការប្រហាក់ប្រហែលតែមួយដូចគ្នា ។

មាត្រា ៤២.- ការបង្វែរពីប្រការមួយ ទៅប្រការមួយ. ពីកថាខ័ណ្ឌមួយ ទៅកថាខ័ណ្ឌមួយ ឬវាក្យខ័ណ្ឌមួយទៅវាក្យខ័ណ្ឌមួយ ដែលនៅក្នុងជំពូកតែមួយ ត្រូវបានអនុញ្ញាតិដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៤៣.- ក្រឹត្យទាំងឡាយរបស់រាជរដ្ឋាភិបាល ដែលធ្វើឡើងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចបែងចែកបន្ទុកដែលកត់ត្រាទៅតាមជំពូកចំណាយជតព្រាងទុក ក្រោមរូបភាព

នៃឥណទានបំពេញបន្ថែម ជាគុណប្រយោជន៍ដល់ជំពូកផ្សេងៗរបស់ក្រសួង ឬ អង្គការប្រហាក់ប្រហែលនានា ដើម្បីត្រៀមចំណាយឥតព្រាងទុក ។

មាត្រា ៤៤._ ឥណទានដែលក្លាយទៅជាមិនមែនមុខសញ្ញាប្រើប្រាស់ក្នុងកំឡុងនៃឆ្នាំ អាចត្រូវបានលុបចោលដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោយពីបានទទួលពត៌មានពីក្រសួង ឬអង្គការប្រហាក់ប្រហែល ដែលពាក់ព័ន្ធ ។

មាត្រា ៤៥._ នៅពេលដែលការវិវត្តន៍នៃចំណូល និងចំណាយលេចចេញឱ្យឃើញនូវការបាត់តុល្យភាពនៃថវិកា នោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចចេញជាប្រកាសរាំងខ្ទប់មួយចំណែក ឬទាំងមូលនៃឥណទានដែលបានអនុម័តនៅក្នុងថវិកា។ ក្នុងករណីការបាត់តុល្យភាពនេះមានលក្ខណៈធ្ងន់ធ្ងរ រាជរដ្ឋាភិបាលអាចធ្វើនីតិវិធីតាមក្រឹត្យ និងលើសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយលុបចោលមួយចំណែក ឬទាំងស្រុងនៃឥណទានដែលបានអនុម័តក្នុងថវិកា។

មាត្រា ៤៦._ ឥណទានបំពេញបន្ថែម អាចត្រូវបានអនុម័តដោយក្រឹត្យ របស់រាជរដ្ឋាភិបាល ដោយផ្អែកលើរបាយការណ៍ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ថែមពីលើថវិកាដែលកត់ត្រានូវជំពូកចំណាយឥតព្រាងទុក ក្នុងករណីមានគ្រោះធម្មជាតិ ឬភាពចាំបាច់ជាបន្ទាន់ដល់ផលប្រយោជន៍ជាតិ ឥណទានទាំងនេះត្រូវអនុម័តច្បាប់ហិរញ្ញវត្ថុបន្ថែមមួយ ដែលត្រូវឆ្លងយោបល់យល់ព្រមពីសភាជាតិជាបន្ទាន់ភ្លាម កាលបើស្ថានការពិសេសទាំងនេះ ត្រូវបានចប់សព្វគ្រប់ ។

មាត្រា ៤៧._ ការកែប្រែផ្សេងៗទៀតនៃច្បាប់ហិរញ្ញវត្ថុ អាចធ្វើទៅបាននៅកំឡុងនៃឆ្នាំថវិកា ជាវត្ថុបំណងនៃច្បាប់ហិរញ្ញវត្ថុបន្ថែម ដោយឆ្លងសភាជាតិ ក្នុងលក្ខខ័ណ្ឌដូចគ្នានៃច្បាប់ហិរញ្ញវត្ថុ ។

## ជំពូក ៧
## អំពីគោលការណ៍ទូទៅ នៃការអនុវត្តន៍ថវិកា

មាត្រា ៤៨._ការអនុវត្តន៍កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ និងគណនីពិសេសរបស់ធនាគារ ជាភារកិច្ចរបស់អាណាប័ក និងគណនេយ្យករ ។ អាណាប័ក និងគណនេយ្យករសាធារណៈ មានមុខងារវិសមិតភាពពីគ្នា ។

រដ្ឋមន្ត្រី និង ប្រធានអង្គការសាធារណៈប្រហាក់ប្រហែល ជាអាណាប័កដើមនៃថវិការដ្ឋ ចំពោះផ្នែកចំណូលដែលបានមកពី " ផ្នែក " របស់ខ្លួន ។ ចំពោះផ្នែកចំណាយរដ្ឋបាលកណ្តាល និង អង្គភាពក្រៅ ក្រោមឱវាទតាមខេត្តនានា រដ្ឋមន្ត្រី និង ប្រធាន

អង្គការសាធារណៈប្រហាក់ប្រហែល ជាអ្នកបញ្ជា"អាណាប័ក"ថវិកាតាមផ្នែករៀងៗខ្លួន ។

រដ្ឋមន្ត្រី ប្រគល់សិទ្ធជូនអភិបាលក្រុង និង អភិបាលខេត្ត ជាប្រតិភូបញ្ជាចំណាយក្នុងកិច្ចប្រតិបត្តិការ ហិរញ្ញវត្ថុ ថវិការដ្ឋ ក្នុងមណ្ឌលនៃខេត្ត ក្រុងរបស់ខ្លួន ។

បទបញ្ជាគណនេយ្យសាធារណៈជ្រើសតាំងប្រភេទមន្ត្រី ដែលអំណាចនៃអាណាប័ក ដើមខ្សែត្រូវបានយល់ព្រមផ្តល់ជូន ឬ ដែលអាចជំនួសអាណាប័កដើមខ្សែក្នុងករណីអវត្តមាន ឬមានធុរៈ ។ សិទ្ធអំណាចដែលបើកឱ្យ ឬ ការចុះហត្ថលេខា ត្រូវធ្វើឡើងក្នុងក្រឹត្យមួយដែលចាំបាច់បញ្ជាក់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៤៩.– ចំណាយដែលត្រូវធ្វើឡើងក្នុងលើថវិការដ្ឋទូទៅ, លើថវិកានានា និងលើគណនីពិសេសរបស់រតនាគារ ត្រូវឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុជាមុន ដែលជាក្របខ័ណ្ឌមន្ត្រីរាជការនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

ក្រឹត្យរបស់គណៈរដ្ឋមន្ត្រីនឹងកំណត់ទិសដៅភារៈកិច្ច និងលក្ខណៈនៃការត្រួតពិនិត្យនេះព្រមទាំងបែបបទបំពេញការងាររបស់ខ្លួន ។

មាត្រា ៥០.– ចំណាយក្នុងការសាងសង់ ឬ ទិញសំភារៈផ្សេងៗក្នុងថវិកាទូទៅរបស់រដ្ឋ និង ក្នុងគណនីពិសេសរបស់រតនាគារត្រូវស្ថិតនៅក្រោមនីតិវិធីនៃការចេញថ្លៃជាសាធារណៈ ។ នីតិវិធីនេះ ត្រូវកំណត់ជាក្របខ័ណ្ឌដោយគណៈរដ្ឋមន្ត្រី តាមសេចក្តីស្នើរបស់រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

មាត្រា ៥១.– កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យរដ្ឋ ត្រូវប្រមូលផ្តុំនៅក្នុងរតនាគារសាធារណៈមួយ ហើយត្រូវបានអនុវត្តតាមប្រព័ន្ធគណនេយ្យសាធារណៈ ។

មាត្រា ៥២.– គណនេយ្យករសាធារណៈ ទទួលបន្ទុកការធានាចំណូល, ទូទាត់ចំណាយ, រក្សាការពារមូលនិធិ, តម្លៃ, ផលិតផល និងវត្ថុធាតុដែលជាកម្មសិទ្ធ ឬប្រគល់ការទុកចិត្តឱ្យអង្គការសាធារណៈ។ គណនេយ្យករសាធារណៈ មានឋានៈជាអ្នកធានាការអនុវត្តន៍កិច្ចប្រតិបត្តិការទាំងនេះហើយគ្រប់គ្រងមូលនិធិទាំងបញ្ចូល ក៏ដូចជាបញ្ចេញពីបេឡា ។

មាត្រា ៥៣.– គណនេយ្យករសាធារណៈត្រូវបានតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទៅតាមសារលិខិតផ្សព្វផ្សាយ ។ អ្នកទាំងនេះ ស្ថិតនៅក្រោមអាជ្ញាធរផ្ទាល់ និងផ្តាច់មុខរបស់រដ្ឋមន្ត្រីក្រសួងផ្ទាល់ ។

មុននឹងចូលបំរើការងារ, អ្នកទាំងនេះ ត្រូវធ្វើសច្ចាប្រណិធានតាមសារលិខិតផ្លូវការ ក្នុងរូបភាព និង នៅមុខអាជ្ញាធរមានសមត្ថកិច្ច ។

អ្នកទាំងនេះត្រូវបានទទួលការទុកចិត្តផ្ទាល់ពីអាណាប័ក, ហើយប្រសិនជាមានពិរុទ្ធភាពនេះចេញគេរ

សាធារណៈ ផ្សេងទៀត ដែលមានទំនាក់ទំនងជាមួយគ្នា ។

មាត្រា ៥៤.- ក្រោមលក្ខខណ្ឌវិធានការណ៍ដោយឡែក ដែលមាននៅក្នុងច្បាប់នេះ និងនីតិកម្ម-បទបញ្ញា ដែលពាក់ព័ន្ធ, ការអនុវត្តន៍កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ ត្រូវប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌ នៃ ប្រព័ន្ធគ្រប់គ្រង ។

មានតែចំណូលដែលបានបង់ចូល និងចំណាយដែលចេញអាណត្តិចំណាយរយៈពេលដប់ពីរខែ នៃឆ្នាំថវិកា ដែលចាត់ទុកជារបស់ការងារគ្រប់គ្រង និង ថវិកា ។

មាត្រា ៥៥.- ការទូទាត់ទូទៅ នៃគណនេយ្យសាធារណៈនឹងត្រូវកំណត់លក្ខខណ្ឌ ហើយកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងគណនេយ្យដែលស្តែងឡើងចេញពីការអនុវត្តន៍ច្បាប់ហិរញ្ញវត្ថុ ត្រូវប្រតិបត្តិតាមលក្ខខណ្ឌទាំងនេះ ។

## ភាគបួន

## អំពីបទបញ្ញានៃ ថវិកា

មាត្រា ៥៦.- បទបញ្ញានៃថវិកា ជាកម្មវត្ថុនៃច្បាប់មួយ ។

មាត្រា ៥៧.- សេចក្តីព្រាងច្បាប់ ទូទាត់ពិនិត្យកត់ត្រានូវចំនួនទឹកប្រាក់ជាស្ថាពរ នៃការបង់ចូលចំណូល និង នៃអាណាប័ណ្ណចំណាយ ដែលបានធ្វើក្នុងអំឡុងការគ្រប់គ្រង ។ សេចក្តីព្រាងច្បាប់នេះ បដិសេធចោលឥណទាន ដែលមិនបានប្រើប្រាស់ ហើយលើកឡើងឱ្យឃើញលទ្ធផលហិរញ្ញវត្ថុពិតនៃឆ្នាំ ដែលត្រូវដាក់បញ្ចូលក្នុង " គណនីលទ្ធផលនៃរតនាគារ " ក្រោយការដកចេញចំនួនទឹកប្រាក់ដែលនៅសល់ទំនេរ លើឥណទានជាយថាហេតុសំរាប់ការចាត់ចែងពិសេស ។

មាត្រា ៥៨.- សេចក្តីព្រាងច្បាប់ទូទាត់ត្រូវបានតាក់តែងដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើមូលដ្ឋាននៃគណនីពិសេសទាំងឡាយ ដែលអ្នកបញ្ជាចំណាយ ត្រូវបង្ហាញនូវកិច្ចប្រតិបត្តិការចំណាយរបស់ខ្លួន និង គណនីគ្រប់គ្រង នៃគណនេយ្យករសាធារណៈ ដែលដាក់ក្រោមការត្រួតពិនិត្យរបស់ក្រុមពិនិត្យគណនីជាមុន ។

មាត្រា ៥៩.- ក្រុមពិនិត្យគណនីជាស្ថាប័នជាន់ខ្ពស់ នៃការត្រួតពិនិត្យហិរញ្ញវត្ថុ ។ ក្រុមនេះពិនិត្យគណនីទាំងឡាយ និងការគ្រប់គ្រងសេដ្ឋកិច្ចរបស់សហគ្រាសសាធារណៈ ។ ក្រុមនេះវាយតំលៃ [illegible] ជំនួយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលរដ្ឋយល់ព្រមអោយដល់ផ្នែកឯកជន ។

សមត្ថកិច្ចរបនាសម្ព័ន្ធ និង និតិក្រមនៃអន្តរាគមន៍របស់ក្រុមត្រួតពិនិត្យគណនី ត្រូវបានកំណត់ដោយច្បាប់ ។

មាត្រា ៦០._ ប្រតិបត្តិការដែលបង្ហាញដោយសេចក្តីព្រាងនៃច្បាប់ទូទាត់ ត្រូវបានលាតក្នុងតារាងទាំងឡាយដែលបង្ហាញ :

១ _ ចំពោះចំណាយនៃថវិកាទូទៅ : ការគ្រោងទុកដើមដំបូង ការអនុញ្ញាតិថ្មី និងបញ្ជាចំណាយបែងចែកតាមក្រសួង ឬតាមអង្គការថ្នាក់ប្រហាក់ប្រហែល តាមប្រភេទ និងតាមជំពូក ។

២ _ ចំពោះចំណូល : ការគ្រោងទុកដើមដំបូង ព្រមទាំងការកែប្រែ និងការប្រមូល ដែលញែកតាមប្រភេទ តាមជំពូក និងតាមប្រការ ។

៣ _ ការប្រៀបធៀបទឹកប្រាក់សរុបនៃការគ្រោងទុកនៃចំណូល និងចំណាយ និងការកែប្រែដែលបានធ្វើ. ប្រសិនជាមាន. ជាមួយនឹងសមិទ្ធិកម្មសំរាប់ថវិការបស់រដ្ឋបាលសាធារណៈនិមួយៗ ។

មាត្រា ៦១._ ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃ ព្រះរាជាណាចក្រកម្ពុជា អនុម័ត នៅថ្ងៃ ទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ នាសម័យប្រជុំរដ្ឋសភា លើកទី ១ និតិកាលទី ១ ។

ភ្នំពេញ.ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

ប្រធានរដ្ឋសភាស្តីទី.

សឺន_សាន់រ៉េត្តី